**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍**

**សំណុំរឿងសភាព្រហ្មទណ្ឌ**
លេខ : ២៥២
ចុះថ្ងៃទី ១៤-៣-២០១៤
**សាលដីកា**
លេខ : ៧៩ក្រIVអ
ចុះថ្ងៃទី ១៧-១០-២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី ១៧-១០-២០១៤ ដោយមានសមាសភាពដូចខាងក្រោម :

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

លោក [redacted]

ដើម្បីជំនុំជម្រះ លើបណ្តឹងសុំស្រូបទោស នៃសំណុំរឿងព្រហ្មទណ្ឌលេខ ២៥២ ចុះថ្ងៃទី ១៤-៣-២០១៤ របស់សាលាឧទ្ធរណ៍ ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៤ របស់ទណ្ឌិតឈ្មោះ [redacted] សំបូរ ដោយមានការបញ្ជាក់ពីប្រធានពន្ធនាគារ នៅមណ្ឌលកែប្រែទី១ បានដាក់ពាក្យបណ្តឹងគោរពចូលមក ឯកឧត្តមប្រធានសាលាឧទ្ធរណ៍ សំណើសុំស្រូបទោសបញ្ចូលគ្នា ចំពោះសំណុំរឿងចំនួន ០៤រឿង ។

**សំណុំរឿងទី១**

-សំណុំរឿងព្រហ្មទណ្ឌលេខ ៣២៤ ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ ។

-បានឃើញ : សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ សម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៥៣ -ង- ចុះថ្ងៃទី ១៣-៣-២០០៩ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៤-៤-២០០៦ របស់ឈ្មោះ [redacted] សំបូរ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៦ "ឈ" ចុះថ្ងៃទី ០១-៣-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤៩៧

៣-បន្តឃុំខ្លួនឈ្មោះ [redacted] សំបូរ តាមមាត្រា ៣៥៣ និង៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៤-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៣-៣-២០០៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សំបូរ ។

បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ : សេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌ លេខ ៣៦ "ឈ" ចុះថ្ងៃទី ១-៣-២០០៦ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សំបូរ ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ ស្នាក់នៅភូមិដើមខ្និត សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ មុខរបរមិនពិតប្រាកដ នៅលីវ ឪពុកឈ្មោះ [redacted] សម្បត្តិ "រ" ម្តាយឈ្មោះ [redacted] មឿន "រ" ដាក់ពន្ធនាគារកំណត់កំណត់៥ឆ្នាំ គិតចាប់ពីថ្ងៃអនុវត្តសាលក្រមមុនៗរួចពីបទ ប្លន់ (ដោយវាយយកលុយ) ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤-៧-២០០៥ តាមមាត្រា៦នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-សាលក្រមនេះ ជំនុំជម្រះនិងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីសំរេចបើកផ្លូវប្តឹងទាស់រយៈពេល១៥ថ្ងៃ និងប្តឹងឧទ្ធរណ៍រយៈពេល ២ខែ ។

## <u>សំណុំរឿងទី២</u>

-សំណុំរឿងព្រហ្មទណ្ឌលេខ ១៨៧៦ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ : សេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌ លេខ ១៦៥ "ឈ" ចុះថ្ងៃទី ២៣-១១-២០០៥ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ផ្តន្ទាទោសជនជាប់ចោទ :

-ឈ្មោះ [redacted] សំបូរ (ហៅម៉ៅ) ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករ ស្នាក់នៅ [redacted] ។

-ឈ្មោះ [redacted] រិទ្ធារិទ្ធ (ហៅតូ) ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបរគ្មាន ស្នាក់នៅ [redacted] ។

កំណត់ដាក់ពន្ធនាគារម្នាក់ៗចំនួន៥ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួនពីបទ "ប្លន់" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៣-៧-២០០៥ តាមមាត្រា៦នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។ ចំពោះឈ្មោះ [redacted] ប៊ុណ្ណារិទ្ធ គិតចាប់ពីថ្ងៃចាប់ខ្លួនបាន ។

២-បង្គាប់ឱ្យជនជាប់ចោទរួមសងកង់ទៅជនរងគ្រោះវិញ បើមិនសងត្រូវដាក់គុកបង្ខំរូបកាយ ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទកំបាំងមុខ [redacted] ប៊ុណ្ណារិទ្ធ សំរេចបើកសិទ្ធប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

## <u>សំណុំរឿងទី៣</u>

-សំណុំរឿងព្រហ្មទណ្ឌលេខ ១៧០០ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ : សេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌ លេខ ១៣៤ "គ" ចុះថ្ងៃទី ២៩-១១-២០០៥ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ផ្តន្ទាទោសឈ្មោះ [redacted] សំបូរ (ហៅម៉ៅ) ភេទប្រុស អាយុ១៩ឆ្នាំ ដាក់ពន្ធនាគារចំនួន០៥ឆ្នាំ (ប្រាំឆ្នាំ) គិតចាប់ពីបានទទួលរងទណ្ឌកម្ម តាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ១៦៥ "ឈ" ចុះថ្ងៃទី ២៧-១១-២០០៥ របស់តុលាការក្រុងភ្នំពេញ រួចពីបទប្លន់ "វាយប្រជាជនយកប្រាក់" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០១-៦-២០០៥ តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-ផ្តន្ទាទោសឈ្មោះ [redacted] (ហៅគុប,ហៅម៉ៅ) ភេទប្រុស អាយុ២៧ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបានពីបទប្លន់ (វាយយកប្រាក់ប្រជាជន) ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០១-៦-២០០៥ តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៣-ផ្តន្ទាទោសឈ្មោះ [redacted] រិទ្ធ (ហៅតូ) ភេទប្រុស អាយុ២២ឆ្នាំ ដាក់ពន្ធនាគារចំនួន០៥ឆ្នាំ(ប្រាំ) គិតចាប់ពីថ្ងៃចាប់ខ្លួនបានពីបទប្លន់(វាយយកប្រាក់ប្រជាជន) ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០១-៦-២០០៥ តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៤-ទុកសិទ្ធិឱ្យដើមបណ្តឹងប្តឹងទាមទារសំណងរដ្ឋប្បវេណីទៅតុលាការរដ្ឋប្បវេណី ។

៥-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សំបូរ (ហៅម៉ៅ) កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] និង [redacted] រិទ្ធ សំរេចបើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

## សំណុំរឿងទី៤

-សំណុំរឿងព្រហ្មទណ្ឌលេខ ១៦៩៨ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ : សេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ១៤៣ "ឈ" ចុះថ្ងៃទី ២៩-១២-២០០៥ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ផ្តន្ទាទោសលើឈ្មោះ [redacted] សំបូរ ភេទប្រុស អាយុ១៩ឆ្នាំ និងឈ្មោះ [redacted] វិទ្ធារិទ្ធ ភេទប្រុស អាយុ២២ឆ្នាំ ដាក់ទោសអនុវត្តក្នុងពន្ធនាគារម្នាក់ៗកំណត់រយៈពេល០៥(ប្រាំ)ឆ្នាំ គិតពីថ្ងៃឃុំខ្លួនតទៅ ពីបទ ប្លន់ (វាយយកលុយ) ប្រព្រឹត្តនៅសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ កាលពីថ្ងៃទី ១០-៧-២០០៥ តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-ផ្តន្ទាទោសលើឈ្មោះ [redacted] ប៊ុណ្ណារិទ្ធ ភេទប្រុស អាយុ២៧ឆ្នាំ ដាក់ទោសអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល៥(ប្រាំ)ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបានតទៅពីបទ ប្លន់(វាយយកលុយ) ប្រព្រឹត្តនៅសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ កាលពីថ្ងៃទី ១០-៧-២០០៥ តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៣-ទុកសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីនាពេលក្រោយ ។

៤-សាលក្រមនេះជំនុំជម្រះនិងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សំបូរ និងឈ្មោះ [redacted] វិទ្ធារិទ្ធ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ប៊ុណ្ណារិទ្ធ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]

សម្រេចបើកផ្លូវប្តឹងទាស់និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

## នាពេលសវនាការ

-ទណ្ឌិតឈ្មោះ [redacted] សំបូរ (វត្តមាន)

-លោក [redacted] ជាវី មេធាវីការពារទណ្ឌិត (វត្តមាន)

ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង

សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ :

-យោងតាមពាក្យសុំស្រុបទោសចុះថ្ងៃ ០៧-៣-២០១៤ របស់ទណ្ឌិតឈ្មោះ [redacted] សំបូរ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ។ នៅចំពោះមុខសវនាការសាលាឧទ្ធរណ៍ទណ្ឌិត [redacted] សំបូរ ឆ្លើយបញ្ជាក់ថាពេលបានចេញពន្ធនាគារ ខ្លួននឹងកែប្រែខ្លួនជាមនុស្សល្អក្នុងសង្គមជាតិ ហើយមន្ត្រីអនុរក្សពន្ធនាគារក៏បានបញ្ជាក់ថា ទណ្ឌិត [redacted] សំបូរ មិនបានបង្កបញ្ហាដល់ទណ្ឌិតដូចគ្នា ឬក្នុងពន្ធនាគារទេ ។

ហេតុនេះ យោងតាមមាត្រា ៥០១ នៃក្រមនីតិវិធីទព្រហ្មទណ្ឌ និងមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ សូមក្រុមប្រឹក្សាពិចារណា និងសម្រេចតាមច្បាប់ ។

-មេធាវី [redacted] ជាវី បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានសុំស្រុបទោសចំនួន៤រឿង ក្នុងការជាប់ពន្ធនាគារ កូនក្តីខ្លួនកែប្រែខ្លួនបានល្អ និងមិនបង្កបញ្ហាដល់អ្នកជាប់ពន្ធនាគារដូចគ្នា ក្នុងរយៈពេលនៃការឃុំខ្លួនរបស់កូនក្តីខ្លួន មានរយៈពេល៩ឆ្នាំហើយ ។ សូមក្រុមប្រឹក្សាពិចារណា ទទួលការស្រុបទោសដល់កូនក្តីរបស់ខ្លួនតាមមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សំណូមពរ : របស់ [redacted] សំបូរ សូមក្រុមប្រឹក្សា ស្រុបទោសដល់ខ្លួនដើម្បីកែប្រែខ្លួន ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារទណ្ឌិត ។

-ក្រោយពីបានពិនិត្យភស្តុតាងឯកសារនានា ។

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

**<u>សាលាឧទ្ធរណ៍</u>**

**<u>យល់ឃើញថា</u>**:

១-បណ្តឹងសុំស្រុបទោសចុះថ្ងៃ ០៧ ខែមីនា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] សំបូរ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ យោងតាមបញ្ញត្តិមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ជំនុំជំរះបាន ។

-មេធាវី [redacted] ជាវី ការពារសិទ្ធិឱ្យទណ្ឌិត ។

២-តាមសាលក្រមព្រហ្មទណ្ឌលេខ ១៤៣ "ឈ" ចុះថ្ងៃ ២៩-១២-២០០៥ របស់តុលាការក្រុងភ្នំពេញ បានសម្រេចផ្តន្ទាទោសឈ្មោះ [redacted] សំបូរ ភេទប្រុស អាយុ១៩ឆ្នាំ ដាក់ពន្ធនាគារ៥ឆ្នាំ ពីបទ ប្លន់(វាយយកលុយ) ប្រព្រឹត្តនៅសង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ កាលពីថ្ងៃ ១០-៧-២០០៥ ។ សាលក្រមនេះ បានចូលស្ថាពរហើយ ។

៣-តាមសាលក្រមព្រហ្មទណ្ឌលេខ ១៣៤ "គ" ចុះថ្ងៃ ២៩ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ បានសម្រេចផ្តន្ទាទោសឈ្មោះ [redacted] សំបូរ (ហៅម៉ៅ) ភេទប្រុស អាយុ១៩ឆ្នាំ ដាក់ពន្ធនាគារ៥ឆ្នាំ ពីបទ ប្លន់(វាយយកប្រាក់) ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃ ០១-៦-២០០៥ ។ សាលក្រមនេះ បានចូលជាស្ថាពររួចហើយ ។

៤-តាមសាលក្រមព្រហ្មទណ្ឌលេខ ១៦៥ "ឈ" ចុះថ្ងៃ ២៣-១១-២០០៥ របស់សាលាដំបូងក្រុងភ្នំពេញ បានសម្រេចផ្តន្ទាទោសឈ្មោះ [redacted] សំបូរ (ហៅម៉ៅ) ដាក់ពន្ធនាគារ៥ឆ្នាំ ពីបទ ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃ ១៣-៧-២០០៥ ។ សាលក្រមនេះបានចូលជាស្ថាពររួចហើយ ។

៥-តាមសាលក្រមព្រហ្មទណ្ឌលេខ ៣៦ "ឈ" ចុះថ្ងៃ ២៣-១១-២០០៥ របស់សាលាដំបូងក្រុងភ្នំពេញ បានសម្រេចផ្តន្ទាទោសឈ្មោះ [redacted] សំបូរ ភេទប្រុស អាយុ១៩ឆ្នាំ ដាក់ពន្ធនាគារ៥ឆ្នាំ ពីបទ ប្លន់ (វាយយកលុយ) ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃ ១៤-៧-២០០៥ ។ សាលក្រមនេះ ឈ្មោះ [redacted] សំបូរ បានប្តឹងឧទ្ធរណ៍ ។

សាលដីកាព្រហ្មទណ្ឌលេខ ៥៣ "ង" ចុះថ្ងៃ ១៣-៣-២០០៩ របស់សាលាឧទ្ធរណ៍ បានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៦ "ឈ" ចុះថ្ងៃ ០១-៣-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។ សាលដីកានេះ បានចូលជាស្ថាពររួចហើយ ។

៦-ទណ្ឌិតឈ្មោះ [redacted] សំបូរ បានប្រព្រឹត្តបទល្មើសច្រើនប្រភេទដូចគ្នា ការចោទប្រកាន់ដាច់ពីគ្នា ។ សាលាឧទ្ធរណ៍ជាតុលាការចុងក្រោយ គប្បីអនុវត្តស្រូបទោសបញ្ចូលគ្នាតាមមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ។

**<u>ហេតុដូច្នេះ</u>**

**<u>ទនិច្ឆ័យសេចក្តី</u>**

១-ទទួលបណ្តឹងសុំស្រូបទោស ចុះថ្ងៃ ០៧ ខែមីនា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] សំបូរ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-អោយអនុវត្តស្រូបបញ្ចូលគ្នា ទោសដាក់ពន្ធនាគារ៥ឆ្នាំ ក្នុងសាលក្រមលេខ ១៤៣"ឈ" ចុះថ្ងៃ ២៩-១២-២០០៥ ទៅក្នុងទោស៥ឆ្នាំសាលក្រមលេខ ១៣៤ "គ" ចុះថ្ងៃ ២៩-១១-២០០៥ ទៅក្នុងទោស៥ឆ្នាំ សាលក្រមលេខ ១៦៥ "ឈ" ចុះថ្ងៃ ២៣-១១-២០០៥ ទៅក្នុងទោស៥ឆ្នាំ សាលដីកាលេខ ៥៣ "ង" ចុះថ្ងៃ ១៣-៣-២០០៩ ។ ទោសអនុវត្តលើទណ្ឌិតឈ្មោះ សុទ្ធ សំបូរ គឺ១០(ដប់)ឆ្នាំ ។

៣-សាលដីកានេះ ជំនុំជំរះនិងប្រកាសជាសាធារណៈ ចំពោះមុខ សុទ្ធ សំបូរ និងមេធាវី .

-បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

**<u>សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែងនិងកងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះ អោយបានសម្រេចប្រសិនបើមានសំណូមពរ ត្រឹមត្រូវតាមច្បាប់</u>** ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ [illegible] ខែ១២ ឆ្នាំ២០១៤

ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]